ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍

# របាយការណ៍

## កិច្ចប្រជុំក្រុមការងារលេខាធិការដ្ឋានបុរសស្រឡាញ់បុរស និងស្រីស្រស់ប្រយុទ្ធនឹងជំងឺអេដស៍

## ថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០១៦ នៅអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍

### ១-គោលបំណង

គោលបំណងនៃកិច្ចប្រជុំ ការពិភាក្សារៀបចំរបៀបវារៈកិច្ចប្រជុំប្រចាំត្រីមាសនៃក្រុមការងារបច្ចេកទេសបុរសស្រឡាញ់បុរស និងស្រីស្រស់ប្រយុទ្ធនឹងជំងឺអេដស៍។

តាមរយៈនៃកិច្ចប្រជុំ សមាជិកក្រុមការងារទាំងអស់រំពឹងថា នឹងបានឯកភាពគ្នាលើរបៀបវារៈសំរាប់កិច្ចប្រជុំប្រចាំត្រីមាសនៃក្រុមការងារបច្ចេកទេសបុរសស្រឡាញ់បុរស និងស្រីស្រស់ប្រយុទ្ធនឹងជំងឺអេដស៍។

### ២-កាលបរិច្ឆេទ ទីកន្លែង និងវត្តមាន

កាលបរិច្ឆេទ : ថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០១៦

ទីកន្លែង : នៅអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍

វត្តមាន : អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ MHC, MHSS,SIT,RHAC,KHANA, FHI360,AHF,and MEC។

### ៣-វិធីសាស្ត្រ : ពិភាក្សារួម

### ៤-លទ្ធផល

នៅថ្ងៃអង្គារ ទី០៧ ខែឧសភា ឆ្នាំ២០១៦ វេលាម៉ោង៩:០០នាទីព្រឹក អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ បានរៀបចំនូវកិច្ចប្រជុំប្រចាំខែរបស់ក្រុមការងារលេខាធិការដ្ឋានបុរសស្រឡាញ់បុរស និងស្រីស្រស់ប្រយុទ្ធនឹងជំងឺអេដស៍ ដែលមានសមាជិកចូលរួមប្រមាណ០៩នាក់ ក្រោមការដឹកនាំកិច្ចប្រជុំដោយ លោកវេជ្ជ.អ៊ឹង សុវណ្ណៈ អនុប្រធាននាយកដ្ឋានបង្ការ ថៃទាំ និងគាំទ្រ នៃអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ។ ជាកិច្ចចាប់ផ្តើម លោកប្រធានកិច្ចប្រជុំ បានថ្លែងអំណរគុណដល់សមាជិកក្រុមការងារលេខាធិការដ្ឋាន ដែលបានចូលរួមប្រជុំនាពេលនេះព្រមទាំងពិនិត្យពិភាក្សាលំអិតលើរបៀបវារៈដែលបានគ្រោងទុក ដោយសម្រេចលទ្ធផលដូចខាងក្រោម៖

ការរៀបចំរបៀបវារៈសំរាប់កិច្ចប្រជុំប្រចាំត្រីមាសនៃក្រុមការងារបច្ចេកទេសបុរសស្រឡាញ់បុរស និងស្រីស្រស់ប្រយុទ្ធនឹងជំងឺអេដស៍៖

១. បទបង្ហាញពីរបាយណ៍ការវឌ្ឍនៈភាពបទអន្តរាគមន៍បង្ការមេរោគអេដស៍ និង ជំងឺអេដស៍ ក្នុងចំណោមក្រុមបុរសស្រឡាញ់បុរស និងស្រីស្រស់ឆ្នាំ២០១៥ បង្ហាញដោយលោក សុខ ពិសី សមាជិកលេខាធិការដ្ឋាន។

២.បទបង្ហាញពីបច្ចុប្បន្នភាពនៃការអនុវត្តន៍សកម្មភាពការងារក្រុមការងាបច្ចេកទេសថ្នាក់ជាតិបុរសស្រឡាញ់បុរស និងស្រីស្រស់ នៅកម្ពុជា បង្ហាញដោយលោក សុខ យ៉ារិទ្ធ សមាជិកលេខាធិការដ្ឋាន។

៣.បទបង្ហាញពីទិសដៅ៩០ ៩០ ៩០ ក្នុងការឆ្លើយតបនឹងមេរោគអេដស៍ និង ជំងឺអេដស៍ជាសកល និងកម្ពុជា បង្ហាញដោយលោក ប៉ូ លីន សមាជិកលេខាធិការដ្ឋាន។

៤.បទបង្ហាញពីផែនការសកម្មភាពបន្ទាប់របស់ក្រុមការងារបច្ចេកទេសថ្នាក់ជាតិបុរសស្រឡាញ់បុរស និងស្រីស្រស់ បង្ហាញដោយលោក ផល សុផាត សមាជិកលេខាធិការដ្ឋាន។

## ៥-សំណូមពរ និងអនុសាសន៍

ស្នើសមាជិកលេខាធិការដ្ឋានផ្ញើនូវរបាយការណ៍ប្រចាំសាមីអង្គការមកអ្នកទទួលបន្ទុករៀបចំបទបង្ហាញឲ្យបានមុនថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៦។

## ៦-ការងារដែលត្រូវធ្វើបន្ត

១.ក្រុមការងារលេខាធិការដ្ឋាននឹងជួបប្រជុំនៅថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៦ ដើម្បីពិនិត្យមើលបទបង្ហាញសំរាប់កិច្ចប្រជុំប្រចាំត្រីមាស នៅអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។

២.រៀបចំកិច្ចប្រជុំក្រុមការងារបច្ចេកទេសថ្នាក់ក្រោមជាតិបុរសស្រឡាញ់បុរស និងស្រីស្រស់ប្រយុទ្ធនឹងជំងឺអេដស៍ នៅថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០១៦ នៅខេត្តសៀមរាប។

៣.រៀបចំកិច្ចប្រជុំក្រុមការងារបច្ចេកទេសថ្នាក់ជាតិបុរសស្រឡាញ់បុរស និងស្រីស្រស់ប្រយុទ្ធនឹងជំងឺអេដស៍ នៅថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១៦ នៅរាជធានីភ្នំពេញ។៚

ភ្នំពេញ ថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០១៦

| បានឃើញ និងឯកភាព | បានឃើញ និងពិនិត្យត្រឹមត្រូវ | អ្នកធ្វើរបាយការណ៍ |
|---|---|---|
| អគ្គលេខាធិការ | ប្រធាននាយកដ្ឋាន | |